## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

------------

# កំណត់ហេតុ

## ស្តីពី

## កិច្ចប្រជុំក្រុមបច្ចេកទេស វាស់វែង វាយតម្លៃ និងផ្ទៀងផ្ទាត់ (MRV)

ឆ្នាំពីរពាន់ដប់បួន ខែកុម្ភៈ ថ្ងៃទីបី វេលាម៉ោងប្រាំបីព្រឹក នៅសណ្ឋាគារ អ៊ីមផារៀល ហ្គាដិន វ៉ាឡា រាជធានីភ្នំពេញមានកិច្ចប្រជុំក្រុមការងារបច្ចេកទេស MRV ក្រោមការដឹកនាំប្រជុំដោយលោក **យន សារ៉េត** អនុប្រធាននាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ នៃរដ្ឋបាលព្រៃឈើ ដោយមានសមាជិកចូលរួមចំនួន១០នាក់ (បញ្ជីវត្តមាន ដូចឯកសារជូនភ្ជាប់)។ កិច្ចប្រជុំនេះបានផ្តោតលើរបៀបវារៈសំខាន់រួមមាន៖

-ការបង្ហាញពីធាតុរបស់ MRV/REL

-ការចែករំលែកព័ត៌មានប្រតិទិនការងាររបស់ក្រុមការងាររ៉េដ+

-ការពិភាក្សាលើតួនាទី និងភារកិច្ចរបស់ក្រុមបច្ចេកទេស MRV

-ការធ្វើបទបង្ហាញ និងកិច្ចពិភាក្សាដំបូងលើផែនទីគោល Zero-Forest Mapping និង ឆ្នាំគោលសម្រាប់រាយការណ៍ AOB

-ការបង្កើតផែនការសកម្មភាពរបស់ក្រុមបច្ចេកទេស MRV ។

ជាកិច្ចចាប់ផ្តើម លោក យន សារ៉េត បានថ្លែងអំណរគុណដល់សមាជិកដែលបានអញ្ជើញមកចូលរួមក្នុងកិច្ចប្រជុំពិភាក្សានេះ។ លោកបានរៀបរាប់អំពីការងារចំបងៗ របស់ក្រុមការងារ MRV មានដូចជា៖ ទីមួយ ធ្វើឲ្យថ្នាក់ដឹកនាំយល់ពីសារៈសំខាន់របស់គម្រោង ទីពីររៀបចំក្រុមការងារបច្ចេកទេសវាស់វែង វាយតម្លៃ និងផ្ទៀងផ្ទាត់ (MRV) និងទីបីរៀបចំសមាសធាតុមួយដែលមានក្រុមអនុវត្តសារពើភ័ណ្ឌ មានអ្នកជំនាញខាងផែនទីសម្រាប់ផ្ទៀងផ្ទាត់ ហើយបន្ទាប់មកអនុវត្តនៅទីវាល និងធ្វើរបាយការណ៍។ លោកក៏បានសង្កត់ធ្ងន់លើគោលការណ៍សំខាន់ៗរបស់MRV ដែលមានចំណុចបីសំខាន់ៗ គឺការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព ដែលកន្លងមកមានរដ្ឋបាលព្រៃឈើ បានអនុវត្តប្រព័ន្ធត្រួតពិនិត្យ វាយតម្លៃ និង រាយការណ៍ (MAR-SFM) ។ បន្ទាប់មកទៀត មានគោលការណ៍រ៉េដ+ ថ្នាក់ជាតិ ដែលផ្សារភ្ជាប់ MRV ជាតិ ជាមួយក្របខ័ណ្ឌសហប្រជាជាតិស្តីពីបម្រែបម្រួលអាកាសធាតុ (UNFCCC) ។ ហេតុដូចនេះ ការពិភាក្សាក្នុងថ្ងៃនេះ នឹងរៀបចំផែនការសកម្មភាពមួយដែលឆ្លើយតបទៅនឹងសកម្មភាពចំបងៗ ស្ថិតនៅក្រោម outcome 4 របស់ផែនទីបង្ហាញផ្លូវរ៉េដ+។ ក្រៅពីនេះផងដែរ ទាមទារឲ្យក្រុមការងារពិនិត្យឲ្យបានម៉ត់ចត់ និងផ្តល់មតិលើចំណុចតួនាទី និងភារៈកិច្ចដែលបានចែងក្នុងលក្ខខណ្ឌការងារ ។ សង្ឃឹមថាកិច្ចពិភាក្សាថ្ងៃនេះ នឹងប្រព្រឹត្តទៅយ៉ាងផុសផុល និងប្រកបដោយផ្លែផ្កា។

**ដំណើរការកិច្ចប្រជុំ**

លោក **ឡេង ជីវិន** បានលើកឡើងថា ទោះបីក្រុមការងារបច្ចេកទេស វាស់វែង វាយតម្លៃ និងផ្ទៀងផ្ទាត់ មានកម្រឹតយល់ដឹងខាងបច្ចេកទេស MRV មិនស្មើគ្នាក៏ដោយ តែសំណូមពរឲ្យសមាជិកក្រុមទាំងអស់យកចិត្តទុកដាក់ និង ពិនិត្យឲ្យបានម៉ត់ចត់លើរាល់ការងារដែលបានផលិតឡើង ពីព្រោះការងារដែលបានសម្រេចនៅក្នុងក្រុមនឹងត្រូវប្រើប្រាស់ជាផ្លូវការ។

បន្ទាប់មកលោក Mathieuu Varijn បានធ្វើបទបង្ហាញរំលឹកឡើងវិញអំពីសមាសធាតុរបស់MRV/REL។

**លោក ឡេង ជីវិន៖** អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO) បានជួយគាំទ្រ outcome 4 នេះជាងមួយឆ្នាំកន្លងមកហើយ ដូច នេះមានសកម្មភាពមួយចំនួនបានធ្វើរួចរាល់ហើយ។

**លោក យន សារ៉េត ៖** តើយើងធ្លាប់មានទិន្នន័យឧស្ម័នផ្ទះកញ្ចក់ពីមុនមកទេ?

**លោក អ៊ុយ កាម៉ាល់៖** សម្រាប់ការងារសារពើភណ្ឌពីមុនយើងបានប្រើ Tier១ របស់ IPCC software ឆ្នាំ១៩៩៦ ឃើញថា កត្តាបំភាយ (Emission Factor) និង ទិន្នន័យសកម្មភាព (Activities Data) មានកំរិតលំអៀងខ្ពស់។ ប៉ុន្តែឥឡូវ យើងប្រើ IPCC software ឆ្នាំ២០០៦ គឺប្រើ Tier ២ និង Tier៣ ដែលតម្រូវឲ្យយើងអភិវឌ្ឍន៍ កត្តាបំភាយ និង ទិន្នន័យសកម្មភាពខ្លួនឯង។ ដោយសង្កេតឃើញថា រដ្ឋបាលព្រៃឈើមានឡូត៍បម្រុងទុកអចិន្ត្រៃយ៍ ចំនួន១០០០ឡូត៍នៅទូទាំងប្រទេស ដូចនេះយើងមានលទ្ធភាពអាចបង្កើតកត្តាបំភាយបានហើយក៏អាចគណនាកម្រិតបំភាយ (Emission Level)បានទៀតផង។ ទោះបីកម្ពុជាមិនទាន់ត្រូវបានតម្រូវអោយមានកត្តាបំភាយផ្ទាល់ខ្លួន ក៏ប៉ុន្តែយើងគួរតែធ្វើអ្វីដែលអាចធ្វើបានទៅបានហើយទទួលបានលទ្ធផលល្អ។ ដូច្នេះក្រុម MRV គួររៀបចំផែនការសកម្មភាព ការងារដោយផ្អែកលើ IPCC software ២០០៦។

**លោក ឡេង ជីវិន៖** ក្រុម MRV នេះជាក្រុមថ្នាក់ជាតិមួយ ដែលសមាជិកនីមួយៗមានភារៈកិច្ចទទួលយកនូវអ្វីដែលបានបង្កើតឡើងរួមគ្នា។

**លោក អ៊ុយ កាម៉ាល់៖** គួរផ្តល់ការរៀបចំធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ទៅស្ថាប័នពាក់ព័ន្ធទាំងអស់ដែលទទួលខុសត្រូវ មានន័យថាក្រសួងពាក់ព័ន្ធទាំងអស់ទទួលខុសត្រូវអនុវត្តនូវតំបន់ដែលខ្លួនគ្រប់គ្រង។ សព្វថ្ងៃនេះក្រុម MRV កំពុងតែដើរតួនាទីយ៉ាងសំខាន់ក្នុងការប៉ាន់ប្រមាណឥណទានកាបូននិង នាំសារអំពីរេដដូនថ្នាក់ដឹកនាំ ដូច្នេះក្រុម MRV គួររៀបចំយន្តការក្នុងការផ្តល់ពត៌មាន។ ជាបន្តលោកបាន ស្នើឲ្យក្រុម MRV គួរត្រូវបានទទួលស្គាល់ជាផ្លូវការ និងសូមអោយពិនិត្យលើសមត្ថភាពក្រុម ថាតើមានចំនួនគ្រប់គ្រាន់ហើយឬនៅ បើនៅតើត្រូវធ្វើដូចម្តេច?

**លោក ឡេង ជីវិន៖** ពុំទាន់ដឹងថាក្រុម MRV នេះ មានការទទួលស្គាល់ដល់កម្រិតណានៅឡើយទេ ហើយក៏ពុំទាន់បានដឹងថាក្រុមនេះអាចមានលទ្ធភាពធ្វើការសម្រេចខាងផ្នែកបច្ចេកទេសបានដល់កម្រិតណាទេ តែដឹងតែថាទម្ងន់ការងារដែរត្រូវអនុវត្ត វាមានវិសាលភាពធំធេងណាស់។ ដូច្នេះការវាយការណ៍ជាចំណុចដ៏សំខាន់ ។

**លោក យន សារ៉េត៖** មានចំណាប់អារម្មណ៍លើចំណុចសំខាន់ៗបី៖ ទីមួយ: ការបង្កើតក្រុមពុំទាន់មានជាផ្លូវការច្បាស់លាស់នៅឡើយទេ ពុំទាន់មានប្រធាន អនុប្រធាន និងមុខងាររបស់សមាជិក ក្រុមនៅឡើយទេ។ ទីពី: ទទួលស្គាល់ថាលោក ជីវិន បានធ្វើការងារទាក់ទង និងរូបភាពផ្កាយរណប នេះជាច្រើនឆ្នាំមកហើយ តែពុំទាន់មាន Tool ឬបច្ចេកទេសណាមួយអោយគេទទួលស្គាល់ ជាលក្ខណៈអន្តរជាតិនៅឡើយ។

ទីបី:ក្រុមការងារនេះ ពុំទាន់មានបែបបទការងារច្បាស់លាស់ ហើយនូវមិនទាន់ដឹងថាត្រូវធ្វើពីណាទៅណា នឹងចេញពីអ្នកណាទៅអ្នកណាទេ។

**លោក Mathieuu Vanrijn៖** MRV Components មានតួនាទីយ៉ាងសំខាន់ចំពោះដំណើរការរេដ+។ នេះជាចំណុចចាប់ផ្ដើមនៃការងារ MRV ក្នុងការបង្កើតផែនការសកម្មភាព ហើយមានដៃគូរជាច្រើនដែលគាំទ្រលើការងារនេះ។ ក្នុងនេះផងដែរ ក្រុមការងារនេះត្រូវដើរតាមប្រតិទិនការងាររេដកម្ពុជា ដើម្បីសម្រេចបានលទ្ធផលល្អ ។

បន្ទាប់មកទៀត លោក **ឡេង ជីវិន** បានធ្វើបទបង្ហាញពីប្រតិទិនការងារ MRV និង ផែនការសកម្មភាពទាក់ទងនឹងការងារ MRV ដែលកម្មវិធី UN-REDD និង CAM-REDD បានដាក់រួមគ្នានៅក្នុងនោះ ការងារមួយចំនួនបានធ្វើរួចជាស្ថាពរ ។

**លោក អ៊ុយ កាម៉ាល់៖** ពេលនេះគួរតែចាត់អត្តិភាពសកម្មភាពជាមុនសិន មុននឹងចាប់ផ្ដើមរៀបចំផែនការសកម្មភាព MRV ។

**លោក យន សារ៉េត៖** តើផែនការសកម្មភាពនេះ ជាផែនការច្រើនឆ្នាំ ឬផែនការប្រចាំឆ្នាំ?

**លោក Mathieuu Varijn៖** គំនិតនេះបានមកពី JICA លោក Hiroshi Nakata ក្រុមគាំទ្ររេដ+ ទាំងអស់គួរតែមានផែនការសកម្មភាពរួមមួយ ដើម្បីបង្កភាពងាយស្រួលដល់ក្រុមការងាររេដ+កម្ពុជា ធ្វើការសម្រេច និងគ្រប់គ្រង។ ហេតុដូចនេះហើយទើបខ្ញុំ និង កញ្ញា Naomi Matsue បានរៀបចំផែនការសកម្មភាពរួមគ្នា បន្ទាប់មកនឹងដាក់ឲ្យក្រុមការងាររេដ+កម្ពុជាធ្វើការសម្រេចឲ្យប្រើប្រាស់ជាផ្លូវការ។

**លោក យន សារ៉េត៖** ដូច្នេះអាចយក Outputs ទាំងអស់មកពិនិត្យមើលថាតើមួយណា ត្រូវធ្វើមុន ហើយសកម្មភាពអ្វីខ្លះដែលត្រូវអនុវត្តន៍។ ឧទាហរណ៍: ការពង្រឹងសមត្ថភាព តើត្រូវពង្រឹងសមត្ថភាពទៅលើអ្វី? ហើយនរណាដែលគួរតែត្រូវពង្រឹងសមត្ថភាព? ហើយក៏ត្រូវធ្វើដូចគ្នាដែរ ចំពោះសកម្មភាពផ្សេងៗទៀត។

**លោក ឡេង ជីវិន៖** គាំទ្រមតិលោក សារ៉េត។ ទោះបីសកម្មភាពដែលបានបង្ហាញមកនេះ ត្រូវបានរៀបចំឡើងដោយអ្នកជំនាញការក៏ដោយ តែវាមិនមែនមានន័យថា ក្រុមការងារត្រូវតែអនុវត្តតាមទាំងស្រុងនោះទេ ហើយត្រូវធ្វើអ្វីដែលខ្លួនឯងអាចធ្វើបានទើបជាការប្រសើរ។

**លោក អ៊ុយ កាម៉ាល់៖** យោងទៅលើកិច្ចពិភាក្សា នឹងការព្រមព្រៀងគ្នានៅក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសលើកទីមួយនៅខេត្តព្រះសីហនុ ក្រុមការងារបច្ចេកទេសនេះ មានពេលធ្វើការតែបីថ្ងៃទេក្នុងមួយខែ ដូចនេះបានន័យថាក្រុមនេះមិនធ្វើការជាអចិន្ត្រៃនោះទេ។ ហើយបើយើងគិតថាទំហំការងារវាមិនសមស្របនឹងពេលវេលាដែលបានកំណត់ឲ្យ យើងត្រូវស្នើសុំពេលបន្ថែមយ៉ាងហោចណាស់ពីរសប្ដាហ៍ក្នុងមួយខែ។ វិធីមួយដែរអាចធ្វើទៅរួចផងដែរ គឺយើងអាចកាត់ផែនការសកម្មភាពពីច្រើនឆ្នាំ មកជាផែនការសកម្មភាពប្រចាំឆ្នាំ ហើយបំបែកជាផែនការសកម្មភាពប្រចាំត្រីមាស ប្រចាំខែ និងប្រចាំសប្ដាហ៍ជាដើម។

**លោក Mathieu Vanrijn៖** អ្នកជំនាញការខាង MRV នឹងត្រូវបានចូលមកជួយក្នុងការងាររបស់ក្រុម ដូចនេះប្រសិនបើក្រុមការងារស្នើសុំពេលបន្ថែមសម្រាប់បំពេញការងារ អាចប៉ះពាល់ដល់លក្ខខណ្ឌការងាររបស់អ្នកសម្របសម្រួល។

**លោក យន សារ៉េត៖** បើដូចនេះ យើងអាចរក្សាទុកពេលវេលាធ្វើការដដែល។

**លោក ឡេង ជីវិន៖** បើតាមពេលវេលាដែលបានចែងក្នុងលក្ខខណ្ឌការងារមានរយៈពេលបីថ្ងៃក៏ពិតមែន តែបើមើលលើទំហំការងារគឺវាត្រូវតែធ្វើច្រើនជាងនេះ។ ដូចលោក Mathieu បាននិយាយហើយ

ថា ការងារនេះត្រូវការអ្នកបច្ចេកទេស និងបទពិសោធន៍ខ្លាំងណាស់ ដូចនេះមានតែក្រុមយើងទេដែលត្រូវធ្វើ មិនអាចមានក្រុមណាមកធ្វើជំនួសបានទេ ហើយប្រហែលជាម្ចាស់ជំនួយនឹងធ្វើការឧបត្ថម្ភលើសកម្មភាពមួយចំនួន។

**លោក យន សារ៉េត៖** ក្រុមការងារអាចនាំយកកិច្ចពិភាក្សា និងមតិយោបល់របស់សមាជិកក្នុងក្រុមព័ត៌មានមួយចំនួនទៀតនៅថ្ងៃនេះ ទៅក្រុមលេខាធិការដ្ឋាន និងថ្នាក់ដឹកនាំ។

## លទ្ធផលនៃកិច្ចប្រជុំលើកទី១

ជាកិច្ចបន្តក្រុមការងារបានចាប់ផ្តើមពិភាក្សាលើផែនការសកម្មភាព ដែលទទួលបានលទ្ធផលដូចក្នុងឯកសារជូនភ្ជាប់ គឺសម្រេចបានផែនការសកម្មភាពការងារ MRV លើចំណុច ៤.១ និង៤.២ និងសកម្មភាពលំអិតរបស់វា ព្រមទាំងបានធ្វើការកែសម្រួលលើពាក្យពេជមួយចំនួនដែលបានចែងក្នុងលក្ខខណ្ឌការងារ(ToR)។

ឆ្នាំពីរពាន់ដប់បួន ខែកុម្ភៈ ថ្ងៃទីប្រាំមួយ វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក ក្រុមការងារMRV បានបន្តកិច្ចប្រជុំនៅសាលប្រជុំរដ្ឋបាលព្រៃឈើ ក្រោមការសម្របសម្រួលដោយលោក **ឡេង ជីវិន** អនុប្រធាននាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ នៃរដ្ឋបាលព្រៃឈើ ដោយមានសមាជិកចូលរួមចំនួន០៩នាក់ (ដូចក្នុងបញ្ជីវត្តមាននៃឯកសារជូនភ្ជាប់)។ កិច្ចប្រជុំនេះបានផ្តោតលើការពិភាក្សាផែនការសកម្មភាពMRVបន្ត។

ជាកិច្ចចាប់ផ្តើម លោក Ono Sigeru បានពន្យល់អំពី MRV និងបង្ហាញការងារខ្លះ ដែលត្រូវធ្វើក្នុងក្របខ័ណ្ឌអន្តរជាតិ និងជាតិ។

## លទ្ធផលនៃកិច្ចប្រជុំលើកទី២

បន្ទាប់មកទៀត ក្រុមការងារបានបន្តកិច្ចពិភាក្សាលើផែនការសកម្មភាពការងារ MRV លើចំណុច ៤.៣ និងសកម្មភាពលំអិតរបស់វា ព្រមទាំងសកម្មភាពគោលនៅក្នុងចំណុច ៤.៤ ដែលទទួលបានលទ្ធផលលំអិតនៅក្នុងឯកសារភ្ជាប់។

សម្រាប់ការប្រជុំលើកក្រោយក្រុមការងារបានសម្រេចកំណត់យកពេញមួយថ្ងៃគឺថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១៤ សម្រាប់រៀបចំកិច្ចប្រជុំបន្ត ដែលទីកន្លែងប្រជុំនឹងជម្រាបជូននៅពេលក្រោយ។

## សំណូមពរ

ក្រុមការងារបានស្នើឲ្យក្រុមលេខាធិការដ្ឋាន ត្រួតពិនិត្យលើឯកសារលក្ខខណ្ឌការងារ(ToR) ដែលបកប្រែជាភាសាខ្មែរ ហើយទាមទារឲ្យអ្នកបកប្រែធ្វើការបកប្រែឲ្យបានគ្រប់ជ្រុងជ្រោយ តាមឯកសារដើម (ឯកសារជាភាសាអង់គ្លេស)បើមិនដូចនេះទេក្រុមការងារMRV/RELនឹងមិនពិនិត្យឡើងវិញម្តងទៀតនោះទេ។

ក្រុមការងារបានស្នើឲ្យបន្ថែមចំណុចមួយចំនួនដូចជា៖

សុវត្ថិភាពការងារ

មន្ត្រីអនុវត្តម្នាក់ៗត្រូវបានលើកទឹកចិត្តក្រោមរូបភាពជាប័ណ្ណសរសើរ រង្វាន់

សូមឲ្យក្រុមMRV មានរចនាសម្ព័ន្ធការងារមួយត្រឹមត្រូវដូចជា អ្នកធ្វើរបាយការណ៍ អ្នកសម្របសម្រួល (ព័ត៌មានលំអិតសូមពិនិត្យមើលឯកសារភ្ជាប់)

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោងដប់ពីរ និងសាមសិបនាទី នាថ្ងៃ ខែ ឆ្នាំ ដដែល ក្រោមបរិយាកាសដ៏ស្និទ្ធស្នាលរីករាយ និងមានការទទួលខុសត្រូវខ្ពស់ ។

**អ្នកធ្វើកំណត់ហេតុ**

**បានឃើញ និង ឯកភាព**

ប្រធានអង្គប្រជុំ